D119601 DC-Cam

# ខេត្តកំពង់ស្ពឺ ឆ្នាំ ២០០១

# ស្រុកគងពិសី

## <u>មន្ទីរសន្តិសុខវៀងអូរភ្លៅ</u>

## កិច្ចសម្ភាសន៍ជាមួយយាយ អ៊ំ ណាប់

ខ្ញុំនៅមិនដឹងថាអ្នកទោសហ្នឹងវាយ៉ាងម៉េចទេ តែគ្រាន់ឮដូចខ្ញុំវ៉ាន់ហ្នឹងគេថាបដិវត្តកំទេច គេយកទៅដាក់គុក កន្លែង ហ្នឹងហើយគេថាខ្ញុំនេះទំនាស់នឹងសហករណ៍បានគេយកទៅដាក់កន្លែងហ្នឹងណា៎កូន ។ តែគ្រាន់អាម៉េចៗ ទៀតខ្ញុំអត់ដឹងដែរទេណា ចុះបើគេយកប្ដីទៅសម្លាប់ យកទៅដាក់គុក យកទៅធ្វើបាប ធ្វើទោសអញ្ចឹង គេថា យើងនែ៎ស្អី យើងហ្នឹងសក្ដិពីរ បងនៅឯវត្តភ្នំប្រាប់នោះ ហ្នុងសក្ដិបី ។ ចា៎! ហ្នុងសង្ឃរាជណា៎កូនយកពីនោះ ហើយបានម៉ោយកឯណេះទៀត ។ ចា៎! ឆ្នាំ ៧៣ ។ គេថាយកតាមខ្សែស្រឡាយពីហ្នឹងម៉ោយកលោកហ្នឹង បានតែពីរថ្ងៃម៉ោយកឯណេះទៀតហើយ ។ ខ្ញុំមានដឹងថាលោកបងហ្នឹងមានទុកទោសអញ្ចឹងអីអត់ដឹងផ្ញើសំបុត្រ ម៉ោថាបងមានទុកធ្ងន់ណាស់ឲ្យប្អូនទៅ ។គ្រូសង្ឃរាជ ។ ដល់ឯណេះទៅហើយគ្រួសារខ្ញុំហ្នឹងធ្វើការនៅអន្តពពេល ដល់ខ្ញុំតាមទៅ ហ្នឹងៗថាអញ្ចឹងឯងទៅមុនទៅចាំខ្ញុំទៅក្រោយ ។ ដល់ម៉ោហ្នឹងម៉ោយកម៉ូតូនៅឯផ្ទះឯណេះកុហក ថាឲ្យទៅយកសាំងទៅមើល បងដែលថាមានទុកហ្នឹង អត់ដឹងថាគេចាប់យកឯណាកូន ថាមានទុក ដឹងឈឺ ដឹងអី ថាអញ្ចេះវិញ ។ ដល់ហើយអញ្ចឹងទៅ ចាប់ហ្នឹងបានពីរថ្ងៃម៉ោយកឯណេះទៅទៀត ម៉ោយកឯណេះទៅហ្នឹង បានដឹងថា ឯណោះគេយកឯណោះដែរ ។ យកបងថ្លៃខ្ញុំហ្នឹងណា៎ ។យកទៅហ្នឹងពួកគ្នាវាហ្នឹងណាកូន ពួកអាពត ហ្នឹង ។ ចា៎!គេអ្នកធ្វើការហ្នឹង ។ ចា៎! ៧៣ដែរ តែមុនឯណេះ(ប្ដីគាត់)ពីរថ្ងៃ ។ ចា៎! ៧៣ហ្នឹងវាខ្លាំងមែនទែន ណាកូន ។ យកទៅយកទៅសម្លាប់នៅវត្តអី នៅខាងជើងវត្តអន្ត វត្តអីល្បង(លោកបង) តើ! គ្រូសង្ឃរាជវត្ត អី គេខាងជើងវត្តអន្ត វត្តហៅវត្តអីលោកបង ហៅវត្តអី ជិតគ្នា អើ! វត្តអន្តប្រាប់ហ្នឹងដែលយកទៅធ្វើ បាបហ្នឹង វត្តអីពូ ហៅវត្តអី ខាងជើងឆ្ងាយម៉ោ វត្តអន្តអញ្ចេះ(ខាងត្បូង) ភ្នំអញ្ចេះ ហើយវត្ត ហ្នឹងទៅ អញ្ចេះ(ខាងជើង) មិនដឹងហៅវត្តអី? នៅស្រុកតាកែវ ស្រុកចំបក់ ។ ដែលសរសេរសំបុត្រម៉ោហ្នឹងវាកុហក យើងហ្នឹងណាស់? ពួកវាហ្នឹងណាស់ យើងមានដឹងអី? បាន អានអី! យើងម៉េចហ៊ានកូនឯងវាឲ្យតែគ្នាគេ ហ្នឹង យើងហ៊ានអ្ហេះ! សរសេរសំបុត្រវាកុហកដាក់ថា លោកមានទុកធ្ងន់ណាស់ គ្រួសារខ្ញុំណាស់ វាហ្នឹងវា សរសេរសំបុត្រ ម៉ោឲ្យម៉ោល្បង(លោកបង)ខ្ញុំហ្នឹង ឲ្យទៅអាងវាយកទៀត វាចាប់ពីណោះម៉ោពីនាក់ទៀត វា ហៅយើងទៅចាប់ទៀត តែនយោបាយ វាថាអ្នកឯណោះមានទុកហ្នឹង យើងអត់មានដឹងថាមានទុកទេ វា ចាប់អីថាតែមានទុកក្រែងឈឺអី មានរឿងអីណាស់កូន ចា៎! ដល់នេះបានដល់ពីរថ្ងៃឡើងបាត់ឯណោះដែរ ខ្ញុំ តាមដើររកបានដឹងថាឯណោះ គេយកឯណោះដែរបានពីរថ្ងៃ ។កូនឯងដែលទៅវត្តហ្នឹង អ៊ំអត់ដឹងទេ វត្តហ្នឹង ជិតវត្តហ្នឹងដែរ តែដល់ពេលយកទៅសម្លាប់ចងអញ្ចេះ កូន អន្ទុយអញ្ចឹង គេទៅរកសពឃើញ តែក្មេងហ្នឹង បែបទៅមន្ទីរហ្នឹង ដើររកអាកូនសិស្សហ្នឹង ដើររក ចបហើយហ្នឹង.........កាលហ្នឹងវាមិនទាន់បានកណ្ដាប់ដៃ

យើងណាទៅ ខ្លាចឡើយហ្នឹង។ អាក្មេងហ្នឹង អាកូនសិស្សហ្នឹងដើររកនែ៎សព ដែលដំណឹងដឹងថាទុកហ្នឹងដែរ យ៉ាងបាន ទៅរកឯហ្នឹងណា៎។ ដល់តែឆាយៗ ដើររកអញ្ចឹងអាក្មេងហ្នឹងសួរថា ពូៗឯងរកអី ខ្ញុំរកសពលោកតា ងន ថាអញ្ចឹងណាស់៎ លោកឈ្មោះ ងន។ ចា៎! ដល់ អញ្ចឹង មិនមែនត្រង់ហ្នឹងទេពូ ត្រង់ណោះទេណា៎ នេះៗកន្លែងនេះដែលផ្នូរលោកវគ្គ នេះ នេះលោកផ្នូរវគ្គនោះ នេះៗ ត្រង់នេះបានលោកបង ងន តាងន ថាអញ្ចឹងណា។ អាក្មេងហ្នឹងណា៎ បែបទំនងអាក្មេងហ្នឹងនៅហ្នឹងមន្ទីរហ្នឹងកាលអាពតណាអាអូន បានណាវាដឹង បើ អញ្ចឹងដូចក្មេងអស់យើងអញ្ចេះ គ្មានអាណាដឹង។ ចា៎! បានដឹងកន្លែងកប់ណា៎ ហើយដល់កប់កូនឯង អង្គុយអញ្ចេះ រួចខ្សែចងទាំងអង្គុយ ហើយយកថ្នូសគ្រប់។ គាស់ម៉ៅឃើញ នៅអញ្ចឹង មានដីពរឯណាបក ចោលនៅតែខោខ្លី ខ្លួនទទេហ្នឹង។ បានថាកូនអើយ ស្លៀកខោស្រេចវា តើមានស្រេចអីយើង យូរបន្តិចដែរអី! ប្រហែល៣ខែអីអ្នក ប៉ុន្មានខែអ្នក? ទៅជាមួយ គី អីហ្នឹង ណា។ មីគី មុនខ្ញុំពីរថ្ងៃ។ ចា៎! វេទនាប្អូនអើយ ថាវាធ្វើបាបនោះហើយ បានម្ហូរស់ហើយបានម្ហូ រស់ហើយវាឲ្យទៅយាមលើភ្នំថាខ្មាំង នៅហ្នឹង ឲ្យយាមម៉ាអន្ទើរប្អូននាក់ៗ នាំគ្នាសំបូងអារ៉ូង គុណម៉ែ គុណឪយើងពិតជាស្លាប់ហើយ អត់រស់ទេ ចុះបើគ្នាច្រើនសីង្ហអី។ ប្ដីអ៊ំជិះម៉ូតូទៅបាត់ទៅណា កុហក ថាឲ្យទៅយកសាំង ខ្ញុំចេះតែចាំមើលមួយម៉ោង ហើយមួយម៉ោងទៀត។ «អញម៉ោ៨ម៉ោវិញហើយ» រួចខ្ញុំនេះចាំតែមើលអត់ឃើញៗ ដល់ល្ងាចទៅដើររក ដើរសួរគ្រប់កន្លែងឃុំ សួរអានេះគេមិនដឹង សួរ អានោះគេមិនដឹង បានតា ហេង ហើយតា សែម ថាអង្គការចាប់ហើយ។ ខ្ញុំថាបើអង្គការចាប់បង ឯងជួយខ្ញុំផងកាលហ្នឹងនៅចាយលុយទេ ជួយខ្ញុំផង ខ្ញុំមិនដឹង ទីពឹងអ្នកណាទេ អត់ស្គាល់គេមានតែបង ឯង ខ្ញុំទីពឹងបងឯង។ ដល់អញ្ចឹង និយាយបានពីព្រឹក ល្ងាចឡើង ប្រធានភូមិគេឃាត់ខ្ញុំថាអត់ឲ្យដើររកទេ ព្រោះអីកាលហ្នឹងបើគេយកប្ដីទៅ គេយកប្រពន្ធទៅសម្លាប់ទៀតហើយ រួចក៏ខ្ញុំលែងហ៊ានដើរកទៅ អង្គុយតែយំ អង្គុយតែ....អ្នកហើយបន្តិចទៅគេថា ហងអើយអញឃើញលោកគ្រូ គាត់ជិះម៉ូតូហ្វេងបាត់ទៅហើយ បន្តិចទៅគេថា ហងអើយអញឃើញគេពាក់ប៉ារ៉េលោកគ្រូ អញឃើញគេ ស្លៀកពាក់ ខោអាវលោកគ្រូ ហើយខ្ញុំនេះគិតតែអង្គុយតែយំទៅ គិតឃើញថាមិនដឹងទីពឹងអ្នកណា ហើយដល់ ទៅឯភ្នំនោះវេទនាកើតទុកស្កម ឈឺ កាន់ឈើច្រត់មានកូនមានចៅអីហ្នឹងគេអត់។ នៅឯភ្នំ«ជ្រៃអូរក្អែ» ខ្ញុំ ខ្លាចគេណាស់ គេឲ្យធ្វើអីធ្វើហ្នឹង។ មូលហេតុដែលគេចាប់យកទៅ ព្រោះគេចោទថាមានទំនាស់ក្នុងសហករណ៍ ហើយម្យ៉ាងទៀត គេថាយើងមានប្ដីមានទោសអញ្ចឹង គេត្រូវយកប្រពន្ធទៅដាក់គុក។ ហើយយើងទៅ យើង កសាងខ្លួនបានៗ មិនបានគេយកទៅវៃចោលទៀតទៅណា យកទៅទាំងឡានៗ ទៅម្ដងមាន៦០ឡានអី។ នៅហ្នឹងគុកជ្រៃអូរក្អែនេះ គេឲ្យទៅជីកព្រែក ជីកព្រែកហើយជីកត្រពាំង។ ជ្រៃអូរក្អែហ្នឹងរាប់មើលប៉ុន្មាន ដណ្ដប់ត្រពាំង ៗជីកអត់បានដេកទេណា។ បន្ទាប់ពីនោះមានគេឲ្យទៅ ស្ទូងរហូតប៉ុន្មានហិកតាឯណោះប្រហែល ពីរគីឡូប្អូនជ្រុង។ បរិវេណគុកនេះ ខាងជើងទៅដល់ឃុំសំរោង កើតទល់ថ្នល់ជាតិ ត្បូងទល់វត្តក្ដីភ្នំពេញ។ អ្នកដែលនៅខាងក្ដីភ្នំពេញហ្នឹងវេទនាជាងខ្ញុំទៅទៀត។ ខ្ញុំហ្នឹងទៅខាងកម្លាំងទីមួយដែលចាស់ទទ្រើកហើយហ្នឹង ណា ហ្នឹងអំណាចដែលថាចង់រស់នោះ ឯងអត់បានដេកទេ ដើរទៅទាំងយប់ ថ្ងៃទូលរែកទៅៗធ្វើរហូតដល់

បាន្កសឹងណោះ ទៅដឹកព្រែកធ្វើប្រពន្ធទឹក ។ បានរស់មកវិញនេះ គឺជាអាយុ១០០ហើយ ។ ពេលដឹកហើយ វាឲ្យមកវិញមក ដល់មកវិញវាឲ្យធ្វើ ជិតៗហ្នឹង វាស់ឲ្យយើងធ្វើទៅតាមកង តាមក្រុមអញ្ចឹងទៀតទៅ ។ មានក្រុម មានកងវាណា៎ ។ អើ! ចុះយកទៅយាមភ្នំអី ហ្នឹងមិនថាស្លាប់អេ្ហះ ឲ្យនៅម៉ុំៗ ត្រង់នេះម៉ុំ ត្រង់នោះម៉ុំ ហើយដែលយើងទៅ ហ្នឹងមិនខំកសាងខ្លួនមិនបាន មិនស្លាប់អេ្ហះ! ។ អ្នកណាដែលរកចំណីឯកជន ក៏យកគ្នាទៅសម្លាប់ ។ ខ្ញុំខំធ្វើការ ណាទឹកឃើញម្តាយនៅផ្ទះ ល្ហេមល្ហាម គាត់កើតទុកទាល់តែស្លាប់ ។ គុក នេះមានទំហំ២គីឡូបួនជ្រុង មានសហករណ៍៦ណានៅក្នុងគុកហ្នឹង វាបង្កើតជាសហករណ៍ ។ ហើយមានកម្លាំង ទី១ ទី២អី អញ្ចឹងទៅណា ។ កម្លាំងស្រួចគេឲ្យហូបបានឆ្ងាញ់ ។ គាត់ពេលសំរាកឡើយ ។ ពេលយប់ដេកបាន បន្តិច បន្តិចហ្នឹង បែបខ្ទង់មួយម៉ោងអីវ៉ាន់ហ្នឹង មួយម៉ោងកន្លះអញ្ចឹងទៅ ។ ទាំងយប់ហ្នឹងគឺដឹកប្រឡាយធ្វើ ទំនប់អី ធើប្រពន្ធ័ភ្លឺ ប្រពន្ធ័អីអញ្ចឹងទៅអំណាចតែខ្លាចគេ ហើយចង់រស់បេះតែទៅៗ ។ មាកន្លែងហ្នឹង មាន អ្នកធំពីរនាក់ តាបែន ហើយនឹងតា ខុន បាក់ជើង ។ តាបែន ចាស់មែនទែនហើយ ។ ហើយតែដល់ពេល ប្រជុំម្តងៗ "ប្រយត្ន័ស្លាប់ណា ខំកសាងខ្លួន គេរែងយកតែដើមៗ ចុងៗគេយកទៅគ្រវាត់ ចោលហើយណា ខំកសាងខ្លួន" ថាដូច្នេះណា ។ មួយថ្ងៃប្រជុំម្តង ជួនកាលក៏ពីរដង ជួនកាលក៏ពីរថ្ងៃ បីថ្ងៃប្រជុំម្តង ។ ប្រជុំហ្នឹង និយាយតែពីខំធ្វើការ ឲ្យតែខំកសាងខ្លួនមិនបានគេយកទៅវ៉ៃចោលទៅណា ដាក់ទាំងឡានៗ អាខ្លះកុហកគ្នាថា អាក្រុមធ្វើស្ពានយកគ្នាទៅវ៉ៃចោល យកគ្នាពីណាមកយកមកដាក់ នៅក្នុងសហករណ៍ហ្នឹង ដល់កសាងខ្លួនមិន បានយកគ្នាទៅវ៉ៃចោលទៀតទៅណា ហើយបេះទេកុហកគ្នា ថាឲ្យទៅធ្វើកន្លែងនេះទៀត កន្លែងនោះទៀត តាមពិតយកគ្នាទៅវ៉ៃចោល ។ កន្លែងក្នុងគុកនោះមិនគួរ បើមើលទេ ដូចប្រែត ។ ឲ្យតែយកប្តីទៅសម្លាប់ គឺយកប្រពន្ធកូនៗទៅដាក់គុកហ្នឹងហើយ ។ គេសង់រោងវែងៗឲ្យយើងនៅ(ចម្ងាយប្រហែលជាង១០ម៉ែត្រ) អ្នក ទោសដេកជាប់ៗគ្នាអញ្ចឹងទៅ ។ រោងនោះប្រក់ស្លឹក ច្រើនរោងណាស់ រាប់មិនអស់ទេ មិនដឹងប៉ុន្មានជួរ ។ តាបែន និង តាខុនជាមេគេ នៅគុកនេះ ហើយមានអ្នកក្រោមបង្គាប់ច្រើនទៀត ។ មានមេក្រុម មេអីត្រួតពី លើអ្នកទោស ។ អ្នកទោសណាដែលកសាងខ្លួនគេសកម្មទៅ គេបានធ្វើមេក្រុមទៅណា ។ អ្នកណាទៅធ្វើការ មួយខែអត់មាន ឈប់អីមួយនាទីហ្នឹង គឺបានធំហើយ ។ អ្នកដែលលួចនេះ លួចនោះគេត្រូវយកទៅសម្លាប់ ចោល ប៉ុន្តែមានការកសាងខ្លះដែរ ។ កសាងបីដងទៅឯងអត់ស្តាប់គេ គេយកទៅវ៉ៃចោល ។ ប្រជាជនដែល រស់នៅក្នុងភូមិមិនសូវជាខុសអីប៉ុន្មានទេពីអ្នកទោស ។ មេគុកនោះបេះជួយកសាងណែនាំថាកុំលួចគេ កុំឯកជន ឲ្យខំធ្វើការប្រយត្ន័ស្លាប់ ។ បានរួចពីម្ងៃទៅម្ងៃ អរណាស់ ។ ប្រជាជនដែលរស់នៅក្នុងគុកជ្រៃអូរក្នោពិតជា ខុសជាមួយប្រជាជនដែលរស់នៅខាងក្រៅគឺអត់ហ៊ាននិយាយលេងសើចអីដូចយើងតាមភូមិអីអត់ទេ អត់ហ៊ាន ទេ ។ អ្នកនៅជ្រៃអូរក្នោគេអត់ឲ្យនិយាយរកអ្នកនៅតាមភូមិទេ ឲ្យតែហ៊ាន និយាយគឺ គេយកទោសទៀត ព្រោះមានគេនៅយាមទៀត អត់ឲ្យយើងលួចចេញមកទេ ។ ពួកកង ឈ្លបគឺនៅឈរយាមនៅលើដើមក្រសាំង ឲ្យតែឃើញពួកយើងមកចាប់យកមានទោសទៀត ។ ពីរឿងម្ហូបម្ហាអីអត់អីទេ ។ ប៉ុន្តែចំពោះការងារអ្នកទោស ធ្វើខ្លាំងជាងក្រៅហើយ ហើយធ្វើកន្លែងផ្សេងគ្នា ។ ប្រធានភូមិជាអ្នករាយការណ៍ពីយើងទៅឲ្យប្រធានគុក ។

មួយថ្ងៃហូបបាយពីរដង ពេលព្រឹកម៉ោង១១-១២ ល្ងាចខ្ទង់ម៉ោង៥ ម៉ោង ៦ហ្នឹង។ បន្ទាប់ពីហូបបាយហើយទៅធ្វើការទៀត ។នាឡិការដែលនៅជាប់ហ្នឹងខ្លួនខ្ញុំសម្រាប់មើលម៉ោង ក៏វាខ្វះយកអស់គ្មានសល់ទេគ្រាន់តែអំបិលបន្តិចបន្តួច ក៏វាប្រមូលយកអស់ដែរ ។ សំរាណមិនបានយូរទេ ប្រហែល១ម៉ោង ២ម៉ោងអីហ្នឹងម្ដងៗ ។ ក្រោកពីយប់ទៅធ្វើការ ។ មេក្រុមជាអ្នកដើរដាសបុកគោះអាគាំងម៉ូងៗ ។ ដល់ពេលឈឺគេឲ្យទៅពេទ្យ ប៉ុន្តែទាល់តែឈឺធ្ងន់ណា៎ ។ ពេទ្យនៅហ្នឹងសហការណ៍ហ្នឹង នៅក្នុងសាលារៀន ។ មានអ្នកជម្ងឺច្រើនណាស់ ។ ពេទ្យនេះសំរាប់ព្យាបាលតែអ្នកជម្ងឺនៅគុកជ្រៃអូរក្នោប៉ុណ្ណោះ ប៉ុន្តែមិនសូវមានម៉ោប្រឡូកប្រឡាំគ្នាទេ ដូចសហករណ៍ខាងលិចភ្នំអញ្ចឹង ពេទ្យហ្នឹងទៅ សហករណ៍ត្រពាំងពោធិ៍ ពេទ្យគេហ្នឹងទៅសហករណ៍ក្ដីភ្នំពេញ ពេទ្យគេហ្នឹងទៅ ប៉ុន្តែយ៉ាប់ណាស់សហករណ៍ក្ដីភ្នំពេញ ទោសច្រើនទោសធ្ងន់ ទោសស្លាប់ហ្នុង ។ សហករណ៍ហ្នឹងនៅក្នុងវត្តតែម្ដង ។ សហករណ៍ក្ដីភ្នំពេញហ្នឹង សម្រាប់ដាក់តែយុវជនទេ ។ ពួកពេទ្យដែលមកធ្វើការនៅក្នុងគុកនេះមិនមែនប្រភេទអ្នកទោសមកធ្វើការជាពេទ្យទេ គឺជាអ្នកមកពីខាងតាកែវមកវិញ ។ ក្នុងមួយសហករណ៍មានពេទ្យម្នាក់សម្រាប់ព្យាបាល ។ ក្នុងមួយសហករណ៍មានប្រជាជនច្រើនណាស់មកពីកន្លែងឆ្ងាយៗ ។ សហករណ៍ទាំង៦នោះគឺសហករណ៍ក្ដីភ្នំពេញ សហករណ៍ខាងលិចភ្នំ(ជ្រៃអូរក្នោ) សហករណ៍ខាងកើតភ្នំ សហករណ៍ត្រពាំងពោធិ៍ សហករណ៍ថ្មបាំង សហករណ៍..........................។ ការរស់នៅក្នុងគុកនេះ គឺមិនឲ្យមានការរស់នៅជាមួយគ្នាទេ សូម្បីតែប្ដីក៏មិនឲ្យ រស់នៅជាមួយគ្នាផង ម៉ោម្ដងៗសឹទ្ធតែលួចលាក់ ។ រាល់ថ្ងៃ១០ ថ្ងៃ២០ គេឲ្យម៉ោជួបមុខគ្នាម្ដង រួចត្រឡប់ទៅវិញទៅ ។ ថ្ងៃ១០ និង ថ្ងៃ២០ហ្នឹងគេធ្វើម្ហូបឲ្យហូបឆ្អែតម្ដង ប៉ុន្តែមិនសូវមានប្រុសៗម៉ោទេ ព្រោះប្ដីគេយកទៅវ៉ៃចោលអស់ហើយ ។ នៅលើកំពូលភ្នំជ្រៃអូរក្នោនេះ អត់មានអីទេ តែវាយកឯងទៅយាមតាមជើងភ្នំ ព្រោះវាថាមានខ្មាំងនៅលើភ្នំហ្នឹង ។ បើខ្មាំងចេញរួចតាមកន្លែងណាហ្នឹង គេយកទោសយើង ។ យាមមានគ្នាបួននាក់សុទ្ធតែស្រីៗ គ្មានកាន់កាំភ្លើងទេ មានតែដៃទទេរហ្នឹង ។ យាមហ្នឹងអង្គុយទល់ខ្នងគ្នាទាំងបួននាក់អញ្ចឹងទៅ ។ មានអ្នកយាមច្រើនណាស់ជុំវិញភ្នំ ។បើសិនជាខ្មាំងចុះពីលើភ្នំម៉ោចំអ្នកណា ហើយឲ្យរួច អ្នកនោះមានទោស ។ ទោសនោះគឺសម្លាប់ចោល ។ អ្នកទោសមានខ្លះត្រូវស្លាប់ដោយសារជម្ងឺ និងខ្លះទៀតស្លាប់ដោយសារសម្លាប់ចោលដោយសាគេកសាងមិនបាន ឬឯកជនច្រើនដងពេកទៅ ។ យកទៅសម្លាប់ទាំងគ្រួសារៗ នៅវេលាម៉ោងមួយយប់ ម៉ោង២យប់ ម៉ោង៣យប់វ៉ាន់ ។ ពេលគេមកហៅយកទៅសម្លាប់ គេកុហកថាយកទៅណេះ ទៅណោះគេមិនប្រាប់ យើងត្រង់ទេ ។ អ្នកដែលយកទៅសម្លាប់គឺគ្មានអ្នកណារស់ទេ ។យកទៅសម្លាប់ហើយ ពួកវាយកខោអាវអ្នកស្លាប់មកចែកចាយក្នុងសហករណ៍ ។ មានឡានធំៗ ដឹកមនុស្សចូលម៉ោ ជួនកាលបានម៉ាយប់ ជួនកាលបានពីរយប់ ជួនកាលបានបីយប់ក៏ដឹកចេញទៅវិញទៅ មិនដឹងដឹកយកទៅណាទេ ។

ខ្ញុំឈ្មោះ អឹ ណាប់ អាយុ ៦៥ រស់នៅភូមិព្រៃខ្វែរ ឃុំវាល ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។

---

## កិច្ចសម្ភាសន៍ជាមួយ ប្រាក់ សារិន

ខ្ញុំឈ្មោះ ប្រាក់ សារិន អាយុ ៤៣ ឆ្នាំ មុខងារបច្ចុប្បន្នមន្ត្រីឃុំវាល ទទួលបន្ទុកការងារសេដ្ឋកិច្ច។ នៅសម័យនោះ(ប៉ុលពត) ខ្ញុំមានអាយុប្រហែល១៦-១៧ឆ្នាំ ហើយខ្ញុំក៏បានបែកចេញពីគ្រួសារទៅនៅកងចល័តឆ្ងាយពីតំបន់នេះទៅ ប៉ុន្តែវាស្ថិតក្នុងស្រុកនេះដែរ បាទ! អ្វីតាមដែលខ្ញុំដឹងនិងតាមការផ្តល់ពត៌មានពីប្រជាពលរដ្ឋដែលគាត់និយាយប្រាប់ខ្ញុំតាមពេលដែលខ្ញុំចូលមកធ្វើការនៅឆ្នាំ១៩៨២ និងក្រោយពេលដែលខ្ញុំចូលមៅស្រុកនេះឆ្នាំ ៧៩ ខ្ញុំដឹងថាគុកនេះគឺជាគុកមួយដែល បើតាមដែលខ្ញុំសន្និដ្ឋានគឺជាគុកគ្រប់គ្រងដោយថ្នាក់តំបន់។ បានថាថ្នាក់តំបន់ គឺថាកាលនោះវាមានតំបន់ គឺតំបន់៣៣ របស់ភូមិភាគនិរតី។ ហើយគុកនេះបើយើងចាត់ទុកថាជាគុកគ្មានជញ្ជាំងទេ ព្រោះគេកំណត់ព្រំប្រទល់លាតពីរគីឡូបួនជ្រុងហ្នឹង។ អញ្ចឹងប្រជាពលរដ្ឋមៅទីនេះ ដូចខ្ញុំបានជំរាបហើយថា វាគឺជាគុកមួយដែលអ្នកទោសភាគច្រើនជាគ្រួសារដែលបដិវត្តកម្មេច។ មានន័យថា ឲ្យតែមានកូន ប្តី ប្រពន្ធនៅក្នុងបន្ទុក ហើយត្រូវបានអង្គការយកទៅសម្លាប់នោះគឺគ្រួសារនោះត្រូវតែយកទៅដាក់ក្នុងហ្នុង មន្ទីរឃុំឃាំងហ្នឹងហើយ ព្រោះបើថាអញ្ចឹង បើតាមយើងសន្និដ្ឋានប្រហែលជាអាចប្រមូលផ្តុំក្នុងការងាយគ្រប់គ្រង ព្រោះសុទ្ធតែជាគ្រួសារដែលមានកំហឹងជាមួយអង្គការរបស់គេហើយ ព្រោះយកប្តីយកកូនយកគ្រួសារគេយកសម្លាប់ អញ្ចឹងយកទៅដាក់ម្តុំ ដើម្បីងាយស្រួលបន្តឹងហើយគ្រប់គ្រង។ អាហ្នឹងតាមយើងដឹង ហើយពេលដែលខ្ញុំចូល ខ្ញុំធ្វើការ ខ្ញុំអាចដឹងខ្លះថា មានសោកនាដកម្មជាច្រើន ក្រោយពីរដ្ឋកម្ពុជាបានរំដោះមៅ ៧៩មៅ ខ្ញុំឃើញថាក្នុងអំឡុង៧៩ ៨០ ៨១ ហ្នឹង យើងឃើញស្លាកស្នាមសាកសពរណ្តៅសាកសពជាច្រើនបានបន្សល់ទុក។ ហើយក្នុងនេះខ្ញុំក៏អាចវាយតម្លៃថា សាកសពខ្លះជាសាកសពដែលស្លាប់ដោយជម្ងឺ ហើយសាកសពខ្លះក៏ប្រហែលជាសាកសពស្លាប់ដោយអំពើសម្លាប់ ឃាដកម្ម។ ហើយសាកសពទាំងនេះ ព្រោះហ៊ានសន្និដ្ឋានបែបហ្នឹងគឺសាកសពដែលជម្ងឺនោះឃើញកប់មានភាពរាយមាយនៅជិតខាងហ្នឹង។ តែបើសាកសពនៅភូមិព្រះស្តេច ភូមិព្រៃក្នុង គឺមានរណ្តៅខ្លះប្រហែលជា១០ម៉ែត្របួនជ្រុង ៥ម៉ែត្របួនជ្រុង ២ ឬ ៣ម៉ែត្របួនជ្រុង ហើយសាកសពនោះគឺពុំមែនមានម្នាក់ទេ ក្នុងមួយរណ្តៅ។ មាន១០ ២០។ អានេះយើងរាប់តែក្បាលដែលយើងគាស់មៅ អញ្ចឹងអាហ្នឹងខ្ញុំសន្និដ្ឋានថាជាសាកសពដែលវាសម្លាប់ហើយ។ ព្រោះលលាដ៍ក្បាលជួនកាលមានផុងលលាដ៍អីអញ្ចឹងទៅ ឃើញមានចំណងជាប់ឆ្អឹង។ អញ្ចឹងយើងឃើញជាក់ស្តែងអញ្ចឹង។ ហើយទ្រង់ទ្រាយប្រជាជននៅទីនោះវាក៏រិតខុសប្លែកពីប្រជាជនរស់នៅក្រៅពីមន្ទីរឃុំឃាំង ព្រោះប្រជាជនដែលរស់នៅក្រៅពីមន្ទីរឃុំឃាំង គេមានសហករណ៍គេមានកងគេដែរ ក៏ប៉ុន្តែ គេបានដើរហើរច្រើន សួរនាំសុខទុកបងប្អូនបាន។ ហើយបើមនោសញ្ចេតនារវាងប្តីប្រពន្ធ វាតឹងដែរ ប៉ុន្តែវាធូរស្រាលជាង ថ្ងៃទី១០ ថ្ងៃ២០ គេវិលមករកគ្រួសារអីអញ្ចឹង ហើយគេមានភាពច្បាប់ទម្លាប់អីវាមិនតឹងប៉ុន្មានទេ។ តែបើតំបន់នោះខ្ញុំអាចដឹងថាតាមការសាកសួរគឺថាវាផ្តាច់មនោសញ្ចេតនារវាងបងប្អូនពីក្រៅនិងក្នុងឃុំឃាំងនោះវាផ្តាច់ ចោលមិនបានទេ ហើយធ្វើការក៏មានកំរិតធ្ងន់ជាងដែរ ព្រោះយើងជាអ្នកទោស។ ហើយនេះគឺប្រជាជនដែលមានសេរីភាព ក៏ប៉ុន្តែប្រជាជនក្រៅក៏គេចាត់ទុកបីដែរ ពេញសិទ្ធ បញ្ញើរ និង ត្រៀម ហ្នឹងក្រោណាំ។សូម្បីតែកងចល័តខ្ញុំក៏គេបែងចែកអញ្ចឹងដែរ កំរិតយុវជន កងចល័តក៏គេបែងចែកអ្នកនេះពេញសិទ្ធ

អ្នកនេះបញ្ជើរ ។ អញ្ចឹងហេតុអីបានជាគេបែងចែកអញ្ចឹង គេថាគេឈរទៅលើបញ្ហាមួយគឺថាជន១៧ ១៨ ។ ប្រជាជន១៨គឺប្រជាជនចាស់ ។ ប្រជាជន១៧គឺប្រជាជន១៧ មេសាគេរំដោះបាន ហើយគេរៀបតាមវណ្ណៈភាព វណ្ណៈភាពគឺថាពីមុនវាមានអ្នកមាន កណ្ដាល ក្រ អញ្ចឹងគេរៀបចំតាមហ្នឹង អញ្ចឹងគេដាក់ត្រៀម ផ្ញើពេញសិទ្ធ ។ អញ្ចឹងតំបន់នេះខ្ញុំអាចដឹងត្រួសៗ គឺជាតំបន់មួយដែលពោរពេញទៅដោយភាពលំបាកវេទនាច្រើន ក្រោយពីយើងបានសើរើឃើញសាកសពជាច្រើនដែលប្រជាពលរដ្ឋយើងស្លាប់ហ្នឹង ខ្ញុំឃើញទាំងប្រជាពលរដ្ឋទាំងកងទ័ពក្នុងឯកសណ្ឋានដែលយើងគាស់បានណា៎ ជួនកាលស៊ីម៉ាលីសុទ្ធ ។ ក្នុងម៉ារណ្ដៅ ២០ ៣០នាក់គឺថាស៊ីម៉ាលីតែម្ដង ហើយស៊ីម៉ាលីសម័យខ្មែរក្រហមហ្នឹង ហើយសម័យហ្នុងគឺច្រើនតែកងទ័ព កងទ័ពហ្នុងគឺ បើកងទ័ពតំបន់ កងទ័ពស្រុកអី មិនមែនស្លៀកស៊ីម៉ាលីទេ ទាល់តែកងទ័ព គេហៅកងពិសេស អង្គភាពពិសេសរបស់ប្រទេសមួយបានស្លៀកបាន ឬក៏ទ័ពភូមិភាគ ។ អញ្ចឹងខ្ញុំគាស់ក្នុងរណ្ដៅមួយហ្នឹងក៏មានស៊ីម៉ាលី ក្នុងម៉ារណ្ដៅហ្នុងគឺមាន២០ ៣០នាក់ ។ ហើយខ្ញុំស៊ើបសួរអញ្ចឹងទៅថា អាហ្នឹងច្រើនមកពីណាខ្លះ? «អូ! អាហ្នឹងគេច្រើនមកពីបូព៌ា» ។ បាទ! បង្វែរទិសយកមកសម្លាប់ ព្រោះកាលនោះយើងដឹងថានៅភូមិភាគបូព៌ាគឺជាចលនាក្បត់មុនគេ ជាមួយសោភឹម អីណា ។ អញ្ចឹងច្រើនយកមកពីហ្នឹង អញ្ចឹងតាំងពីដើមដល់ចប់ខ្ញុំជឿជាក់ថាការសម្លាប់ និងការស្លាប់របស់ប្រជាពលរដ្ឋតាំងពីពេលមានគុក ការសម្លាប់ ការស្លាប់គឺគេមិនកាត់បន្ថយទេរហូតដល់មានការផ្ទុះអាវុធនៅឆ្នាំ១៩៧៩ទើបបញ្ចប់ ។ សូម្បីតែនៅកងចល័តខាងក្រៅដែលខ្ញុំដើរក៏អញ្ចឹងដែរ ពេលដែលចប់ហើយហ្នឹងកាន់តែសម្លាប់ខ្លាំង ។ បងប្អូនខ្ញុំខ្លះក៏ស្លាប់នៅខាងក្រៅគុកដែរនៅពេលដែលប្រទាញប្រទុងគ្នា ។ វៀតណាមទាញបញ្ចូល ខ្មែរក្រហមដេញទៅលើ ។ អញ្ចឹងបើអាណារត់មកគេមកទាន់គឺអាហ្នឹងហើយ ។ ហើយគ្រួសារខ្លះទៀតស្លាប់ច្រើនទៀត ពេលដែលបែកគុកហ្នឹង ព្រោះគុកហ្នឹងវាមានគេចិញ្ចឹមជ្រូក មានជង្រុកស្រូវ ជង្រុកអំបិល ។ ប្រជាពលរដ្ឋយើងគ្រាន់បែករត់ទៅយក ហើយក្នុងកណ្ដាប់ដៃគេ អញ្ចឹងគេស្រាវជ្រាវ អ្នកណាទៅយកខ្លះជ្រូក អ្នកណាទៅយកខ្លះអំបិល អ្នកណាយកស្រូវ ហ្នឹងគេវាយយកទៅហើយ ពេលនោះគឺស្លាប់ក៏ច្រើនដែរ ពេលស្ថិតក្នុងសភាពមួយមិនមានអ្នកណាគ្រប់គ្រងច្បាស់លាស់ហ្នឹង ។

តំបន់៣៣មានស្រុក ៥១ ៥២ ៥៣ ៥៤ ៥៥ ៥៦ ។ ៦ស្រុក ហ្នឹងចំណុះតំបន់៣៣ ហើយបច្ចុប្បន្នបើស្រុក ៥២ បើតាមខ្ញុំដឹងគឺស្រុកសំរោងទង ស្រុកគងពិសី ។ បើ ៥១ វាទៅជាស្រុកភ្នំស្រួច ស្រុកអី ព្រែកក្មេង ជាំសង្កែហ្នុងណា៎ អាហ្នុងវា ៥១ ។ ស្រុក ៥៣ គឺស្រុកបរសេដ ។

ចំពោះចំនួនសាកសព បើតាមខ្ញុំប៉ាន់ស្មាន គ្រាន់តែភូមិព្រះស្ដេចមួយគឺយ៉ាងហោចណាស់គឺ៣០០ ៤០០សាកសពដែរ ព្រោះរណ្ដៅភូមិហ្នឹងមួយពេញទាំងអស់ ហើយបច្ចុប្បន្នប្រជាពលរដ្ឋនៅហ្នឹងទៀត ។ នេះជាចំនួនក្បាលដែលគាស់បាន ហើយបានដឹកទាំងបាវៗយកទៅដាក់នៅបាកករឯណោះ ហើយសល់ខ្លះយើងដឹកមិនអស់យើងរំលាយចោល ។ ចំណែកនៅព្រៃខ្ទុងមួយទៀតក៏ខ្លាំងដែរ ហើយនៅមានអារាត់អារាយខ្លះទៀត ។ កន្លែងសម្លាប់ដែលសំខាន់ធំៗមានពីរកន្លែងគឺនៅភូមិព្រះស្ដេច មួយនិង ព្រៃខ្ទុងនេះពីរ ។ ជនរងគ្រោះសុទ្ធតែយកចេញពីជ្រៃអូរក្មៅនេះដែរ ។

ចំនួនរណ្តៅ ២០ ៣០រណ្តៅដែលប្រជាពលរដ្ឋគាស់នៅភូមិព្រះស្តេច ។ ព្រៃខ្វង បើតាមខ្ញុំដឹងមិនច្រើនប៉ុន្មានទេ ប្រហែល៥ ៦ រណ្តៅទេ ។

ប្រជាជនដែលបានជាប់នៅក្នុងគុកជ្រៃអូរក្តៅហ្នឹង គឺគ្រប់ប្រភេទទាំង៣គឺ បញ្ញើរ ១៧ ១៨ ។ ប្រជាជន១៨ គឺជាប្រជាជនដែលគេកាន់កាប់មុនថ្ងៃ១៧ មេសា ៧៥ ។ គឺជាប្រជាជនដែលតស៊ូជាមួយគេរួមរំលែនំណុល ។ ប្រជាជន ១៨ គឺប្រជាជន ១៨មិនា ឬប្រជាជនចាស់ ។

ចំពោះការប៉ាន់ស្មានចំនួនជនរងគ្រោះវិញ ខ្ញុំមិនអាចដឹងបានទេ ប៉ុន្តែបើលោក **សាមឿន** នៅរតនគីរីហ្នឹងគាត់ច្បាស់ហ្មង គាត់គឺជាមនុស្សម្នាក់ដែលធ្លាប់មានតួនាទី ។ ហើយគាត់រត់ទៅនៅនោះទៅ ដោយសារអីដោយសារមានបញ្ហាខ្លះពីឆ្នាំ៧៩ ។ យើងគាស់រណ្តៅសាកសពប្រហែលជាឆ្នាំ ៨២ ពេលដែលខ្ញុំទៅធ្វើការ ។ កាលនោះខ្ញុំនៅអនុប្រធាននគរបាលឃុំ ។ ហើយប្រជាជនគាស់ខ្ញុំក៏នាំគ្នាទៅមើល ។ ប្រជាជនដែលគាស់នោះគឺគាស់រកមាសទេ ។ ខ្លះគាស់ទៅនៅទាំងឯកសណ្ឋាន ព្រោះខ្ញុំស្គាល់ ។ សម័យនោះខ្ញុំធ្លាប់ធ្វើចលនាម៉ាឆ្នាំគេដែររំលែនំណុល ស្តាយការក្មើងអូសដី ។ ខ្ញុំចូលឆ្នាំ ៧៤ហើយបែកនៅឆ្នាំ៧៥ ព្រោះកាលហ្នឹងឲ្យតែក្មេងពេញអាយុ១៥ ១៦ គេកៀងចេញពីម៉ែឪហើយ ឲ្យទៅធ្វើឈ្លប កងចល័ត និយាយរួមឲ្យទៅជួរមុខ ឲ្យលីលែងរបួសអីអញ្ចឹងទៅណា ។ហើយខ្ញុំគេឲ្យធ្វើទ័ពស្រុក ។ គ្មាននរណាប្រកែកបានទេឲ្យតែដល់អាយុ ។ កងទ័ពពិសេសនោះគឺរបស់ខ្មែរក្រហម សម្លៀកបំពាក់ពណ៌ស៊ីម៉ាលី ពណ៌ត្រួយចេក ។ គេសម្គាល់ថាទ័ពឲ្យតែមានឯកសណ្ឋានហ្នឹងគឺទ័ពភូមិភាគហើយ ។ កងទ័ពនេះច្រើនតែយកមកពីបូព៌ា គេថាពួកសោភឹមហើយហ្នឹង ដែលជាកងទ័ពក្បត់ហើយនាំយកមកសម្លាប់នៅនេះ អង្គការជាអ្នកសម្លាប់ពួកគេ ។ ភូមិភាគនេះ ជាភូមិភាគនិរតី ហើយតាម៉ុកជាអ្នកគ្រប់គ្រង ។ ខ្ញុំស្គាល់គាត់(តាម៉ុក)ម្តងពេលសន្និបាតមហាជនឆ្នាំ៧៦ កាលនោះខ្ញុំនៅកងចល័តស្រុក ។ ពេលសន្និបាតនោះ គាត់ស្លៀកពាក់ខ្មៅ ក្រមាបង់ក ហើយនិយាយទៅកាន់មហាជនថា "នយោបាយរបស់បក្សកម្ពុជាប្រជាធិបតេយ្យត្រូវដើរតាមលទ្ធិម៉ាក្សលេនីន ។ លទ្ធិវាងលទ្ធិសេរីនិងលទ្ធិកុម្មុយនីស្ត ដំណើរទៅមុខប្រទេសសេរីនឹងឈានទៅកាន់ប្រទេសកុម្មុយនីស្តទាំងអស់ ព្រោះសហភាពសូវៀតមួយគឺជាសសរទ្រូងនៃលទ្ធិកុម្មុយនីស បច្ចុប្បន្នប្រទេសនិមួយៗកំពុងតែមានចលនាតស៊ូ កម្មករវើបំរាស់ពីវណ្ណៈជិះជាន់ ។ បដិវត្តន៍យើងគឺជាមានគោលនយោបាយស្មើភាព មិនមានអ្នកមាន មិនមានអ្នកក្រ អញ្ចឹងបដិវត្តន៍យើងគឺជាបដិវត្តន៍មហាលោតផ្លោះ មហាអស្ចារ្យ ។ បដិវត្តន៍ត្រូវតែមានការគាំទ្រពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិ ទៅមុខរបបសេរីនឹងត្រូវរលំរលាយ ពិភពលោកទាំងមូលគឺមានតែបដិវត្តន៍" ។ ប៉ុន្តែគេនិយាយគឺ "បដិវត្តន៍ គឺជាបដិវត្តន៍ដែលមានប្រជាធិប្បតេយ្យ" ។ ការសម្លាប់មនុស្ស ឬមនុស្សស្លាប់នៅគុកជ្រៃអូរក្តៅ គឺមិនបាច់សុំការអនុញ្ញាតិពីថ្នាក់លើទេ គឺកម្មាភិបាលមួយ គេមានសិទ្ធរបស់គេ ។

ទីតាំងគុកជ្រៃអូរក្តៅ ខាងត្បូងជាប់នឹងវត្តសុវណ្ណគីរី ឬវត្តភ្នំពេញ, ខាងជើងជាប់នឹងភូមិសំរោង ឃុំអង្គពេល, ខាងកើតជាប់ផ្លូវជាតិលេខ ៣, លិចជាប់នឹងភូមិឈើទាលជ្រុំ ឃុំវាល ។

---

## កិច្ចសម្ភាសន៍ជាមួយ ប្រាក់ គី

ខ្ញុំហ្នឹងគេយកទៅឆ្នាំ៧៧ ខែ៧ ។ គេយកប្ដីខ្ញុំឆ្នាំ ៧៦ ខែ១ ថ្ងៃទី៥ ។ គេយកខ្ញុំទៅនៅផ្ទះមួយបួនគ្រួសារ ហើយគេឲ្យយើងទៅដេរស្លឹក រែកដីធ្វើដីលេខ១ ២ ហើយស្ទូងដកលើកព្រែក ស្រេចគេប្រើ ។ ហើយដល់នៅយូរៗទៅគេយកទៅធ្វើការរហូតដល់ក្ដីភ្នំពេញឯណោះ កូននៅផ្ទះឯណោះទេ ម៉ោង១០ក៏ដោយឲ្យតែគេឲ្យម៉ោដឹងតែពីម៉ោ ព្រោះអាណិតកូន ។ ជួនកាលទៅធ្វើនៅវត្តចំប៉ាឯណោះ កូនយកទៅដាក់រហូតឯវត្តល្វារ ។ ទៅប្រួតរហូតឯលិចដើមគ្រង ។ ធ្វើម៉េចឲ្យតែបានរស់ ។ បរិវេណមន្ទីរសន្តិសុខនេះមានចម្ងាយ៤គីឡូបួនជ្រុងដល់ត្រាំខ្នារឯណោះ ។ អ្នកស្រុកចូលអត់បានទេ ។ ប្ដីខ្ញុំគេឲ្យទៅដឹកសង្កសី តុអីយកមកដាក់សហករណ៍ដល់គាត់ចេញចូលៗទៅ ដល់ថ្ងៃមួយគាត់សុំខ្ញុំទៅស្រុក ដល់ទៅស្រុកស្រាប់តែបាត់រហូតទៅ ។ ខ្ញុំដើរសួរដែលខ្លួនទើបតែឆ្លងទន្លេទើបបានមួយខែ ដល់ប្រធានសហករណ៍គេហ្នឹង ។ ខ្ញុំសួរថា“បង! អត់ទោសបង ខ្ញុំអត់ឃើញប្ដីខ្ញុំថាឲ្យទៅភ្នំពេញ ឥឡូវអត់ឃើញម៉ោ អង្គការចាប់អី! បងប្រាប់ខ្ញុំឲ្យត្រង់ម៉ោខ្ញុំសោះមិនអាឡោះអាល័យ ។ បើគាត់ខ្ទាំងឲ្យចំជាខ្ទាំងទៅណា ។ដល់ហើយទៅគាត់ថា“ប្រហែលអង្គការចាប់ហើយមើលទៅ” ។ ខ្ញុំសួរទៀតថាចុះបើទោសធ្ងន់ប៉ុន្មាន ទោសស្រាលប៉ុន្មាន គាត់ថាទោសស្រាលប្រហែល៣ខែ ។ ដល់ខ្ញុំចាំមើលទៅអត់ឃើញ រហូតទាល់តែគេមកចាប់ខ្លួនខ្ញុំទៅជ្រៃអូរក្មៅ ។ ពេលគេម៉ោយកខ្ញុំទៅ គេប្រាប់ថាគេយកខ្ញុំទៅជួបជាមួយប្ដីខ្ញុំ “ឥឡូវមិត្តឯងអង្គការឲ្យទៅជួបជុំជាមួយប្ដីនៅជ្រៃអូរក្មៅ” ខ្ញុំថាបងឯងកុហកខ្ញុំទៀតហើយ មិនដឹងខ្ញុំមានទោសអី បងឯងកុំយកខ្ញុំទៅអី ខ្ញុំដឹងថាប្ដីខ្ញុំស្លាប់ហើយ ខ្ញុំថាអញ្ចឹងណា! ។ ថ្ងៃហ្នុងគេយក៦គ្រួសារឲ្យទៅជួបជុំគ្នានៅជ្រៃអូរក្មៅ ។នៅជ្រៃអូរក្មៅ មាន៦សហករណ៍ៈ លិចភ្នំម៉ាសហករណ៍ ដើងភ្នំម៉ាសហករណ៍ ឃុំរាំងម៉ាសហករណ៍ ស្បូងម៉ាសហករណ៍ ត្បូងភ្នំម៉ាសហករណ៍ វត្តចំប៉ាម៉ាសហករណ៍ សំរោងម៉ាសហករណ៍ ថ្មបាំងម៉ាសហករណ៍ ។ក្នុងម៉ាសហករណ៍ដាក់រាប់ម៉ឺននាក់ ។ ជួនកាលមួយថ្ងៃយកចូល៦-៧ឡានចូលសហករណ៍ឯដើងភ្នំអញ្ចឹង ដាំបាយប្រហែល២០ខ្ទះក៏អត់គ្រាន់ដែរ ។ អ្នកទោស អាទើបការហើយម៉ាងៃក៏យកគ្នាម៉ោក្មេងៗក៏មាន ចាស់ជរាក៏យកម៉ោ ឲ្យតែអ្នកនោះមានគ្រួសារអង្គការកំទេច ។អ្នកម៉ោយកខ្ញុំឈ្មោះហុក ប្រធានសហករណ៍ ។

គុកជ្រៃអូរក្មៅស្ថិតនៅក្នុងភូមិដើងភ្នំ ឃុំវាល ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។ គុកនេះបង្កើតប្រហែលជានៅឆ្នាំ ៧៦ ។ ប្រជាជនដែលយកមកដាក់នៅហ្នឹងគឺយកមកពីតំបន់ឆ្ងាយៗ ដូចជាតំបន់ ២៥, ទ្រលាប់, ព្រៃវែង, ស្វាយរៀង............ ។ មូលហេតុដែលគេយកមកដាក់ច្រើននេះព្រោះនេះជាគុកតំបន់ ។ ប្រធានគុកឈ្មោះ ខុន ហើយមានឈ្មោះ តាបែន តាឃុន ។ អ្នកទោសមួយងៃអាចហូបបាយបានពីរពេល ។ ពេលធ្វើការ ម៉ោង៤ចេញទៅហើយ យកកូនទៅដាក់ឲ្យយាយ ។ លុះដល់ពេលល្ងាចម៉ោងប្រហែល៦ ទើបម៉ោពីធ្វើការវិញទំរាំហូបបាយអីហើយម៉ោងខ្ទង់៨-៩ហើយបានជួបកូន ។ មួយថ្ងៃៗមានមនុស្សស្លាប់ច្រើន ។ មានការប្រជុំខ្លះៗពេលយប់ ។ ការប្រជុំនោះគឺឲ្យខំធ្វើការ ។ និងមានសន្និបាតមួយទៀត ស្ដីពី “ខំប្រឹងធ្វើការ

ផារ» បើធ្វើការផាររល្អមិនស្លាប់ទេកុំឲ្យតែលួចបេះបោចដំណាំគេ ។ តាខុន តាបែន ជាអ្នកបើកសន្និបាតហ្នឹង ។ ខ្ញុំឃើញមានដឹកមនុស្សចេញទាំងឡានៗទាំងថ្ងៃ ប៉ុន្តែមិនដឹងជាដឹកយកទៅណាទេ ។ កម្មាភិបាលដែលធ្វើការនៅក្នុងគុកជ្រៃអូរក្អោរនេះ សុទ្ធតែយកមកពីស្រុកក្រៅ ។ អ្នកជាប់ទោសនៅជ្រៃអូរក្អោរ មានស្រីច្រើនជាងប្រុស អ្នកទោសសូម្បីតែចាប់កង្កែបក៏មានទោសដែរ ។

ខ្ញុំឈ្មោះ ប្រាក់ គី អាយុ៥៥ឆ្នាំ រស់នៅភូមិព្រៃខ្វង ឃុំវាល ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។ អ្នកនៅក្នុងគុក និងអ្នកនៅក្រៅគុក ពេលដែលឃើញគ្នាគឺមិនហ៊ានរាករកគ្នាទេ ខ្លាចគេយកទៅវ៉ៃចោល ។ ឲ្យតែដល់ថ្ងៃរៀនសូត្រគឺគេធ្វើឲ្យហូបឆ្ងាញ់ហើយ ។

មូលហេតុដែលដឹងថាមានប្ដីត្រូវបដិវត្តកំទេចព្រោះមានប្រធានភូមិរាយការណ៍ប្រាប់ប្រធានសហករណ៍ថាអ្នកនេះ អ្នកនោះមានប្ដីត្រូវបដិវត្តន៍កម្ទេចហើយ ។

---

## កិច្ចសម្ភាសន៍ជាមួយ មាស លាភ

ដំបូងគេចាប់ឪខ្ញុំទៅ ។ បន្ទាប់មកគេចាប់ខ្ញុំទៅដាក់នៅជ្រៃអូរក្អោរហ្នឹងទាំងពីរនាក់បងប្អូននិងម៉ែ ។ខ្ញុំស្ថិតនៅក្នុងកងភ្ជួរ ។ ពេលភ្ជួរគឺភ្ជួរពីម៉ោង៣ភ្លឺរហូតដល់ម៉ោង១២ថ្ងៃត្រង់ទើបឈប់ ។ ពេលភ្ជួរហើយហ្នឹងអត់ឲ្យឈប់ទេ គេឲ្យឃ្វាលគោទៀត រហូតដល់ម៉ោង៣រសៀល គេឲ្យភ្ជួរទៀតហើយ ។ ហូបបបរ ហូបអត់ឆ្អែតទេ ។ ហូបជាមួយសម្លប្រលិត ។ មួយថ្ងៃពីរពេល បន្ទាប់ពិហូបបាយល្ងាចហើយ មានប្រជុំរាល់ថ្ងៃ ។ កិច្ចប្រជុំស្ដីពីឲ្យខំធ្វើការ ។ កិច្ចប្រជុំមានៈ ថ្ងៃដំបូងប្រជុំប្រធានក្រុម ស្អែកប្រធានកងហា ស្អែកប្រធានកងរយ វិលរហូត ។ ប្រជុំរហូតដល់ម៉ោង៩ ម៉ោង១០យប់ទើបឈប់ ។ សំរាកនៅខាងត្បូងភូមិរាំង ក្នុងផ្ទះមួយសល់ពីដើម ផ្ទះនេះដេកពេញទាំងអស់ អត់មានដាក់ខ្នោះទេ ។

ខ្ញុំអត់មានអីខុសទេ មូលហេតុដោយសារគេចាប់ឪខ្ញុំទៅ ព្រោះកាលនោះគាត់ធ្វើសង្គមកិច្ច អ្នកមើលជម្ងឺគេ គេប្រាប់គាត់ថា យកទៅសួថ្នាំ ហើយក្រោយមកក៏បាត់រហូតទៅ ។ គេចាប់ឪខ្ញុំទៅនៅឆ្នាំ ៧៦-៧៧ ហ្នឹង ។ គ្រាន់តែគេចាប់ឪបានមកខែពីរខែ គេមកចាប់ខ្ញុំទៀត ។ គេប្រាប់ថាឲ្យទៅជ្រៃអូរក្អោរ ។

ពួក១៧ គេឲ្យទៅកាប់ចំការ តាទៅហើយបាត់ហើយ ទៅទាំងឡានៗ ។ ប្រធានធំនៅជ្រៃអូរក្អោរហ្នឹងឈ្មោះ ខុន ។ ខ្ញុំអត់ហ៊ានលួចអីរបស់គេទេ ខ្លាចគេយកទៅវ៉ៃចោល ។ ខ្ញុំធ្លាប់ឃើញគេលួចមាន់ ហើយត្រូវយកទៅសម្លាប់ចោល ។ ពេលរំដោះ ខ្ញុំនៅកំពុងបោកស្រូវនៅវត្តចំបក់ វែកកណ្ដាប់ ពេលនោះខ្វះរត់ទៅលិចទៅ ខ្ញុំរត់មកផ្ទះរាល់ថ្ងៃនេះ ។

ខ្ញុំឈ្មោះ មាស លាភ អាយុ៤១ឆ្នាំ រស់នៅភូមិព្រៃខ្វុង ឃុំវាល ។

## កិច្ចសម្ភាសន៍ជាមួយ មាស រុំ

ខ្ញុំស្ថិតនៅក្នុងកងមិត្តនារី ។ ខ្ញុំឃើញអ្នកផ្សេងៗទៀតខុសដោយសារលួចរកក្ដាម រកអីហូប លួចកម្មសិទ្ធក្រាស ធ្វើនេះធ្វើនោះ ដោយឃ្លានពេក ហើយត្រូវចាប់ខ្លួនយកទៅ ហើយក្រោយម៉ោឃើញយកខោអាវម៉ោវិញភ្លាមៗ ។ពេលម៉ោដល់ ចែកខោអាវទៅដឹងថាអានេះខោអាវមិត្តនេះ អានោះខោអាវមិននោះ នៅជ្រៃអូរក្នោនេះ ចែកចេញជាកងភ្ជួរ កងមើលចៅ កងនារី កងស្រួច ។ កងស្រួចធ្វើការខ្លាំងអាចហូបបាយបានឆ្អែត ។ ខ្ញុំមិនដែលបានជួបមុខបងប្អូនទេ ។

ពេលព្រលឹមឡើង គេទះដៃឡើងៗ មិត្តនារី ដល់ងើបឡើងដាស់គ្នា អ្ហូរ!ងើប ស្រាបតែរឹង ។ ហើយទៅប្រាប់មេកងថាបងៗ មិត្តនេះស្លាប់ហើយ ។ អើ!ស្លាប់ ចុះទៅធ្វើការទៅ ទុកហ្នឹងហើយ ។ ក្នុងមួយយប់ៗមានស្លាប់ពីរបីអត់ខានទេ ស្លាប់ដោយអត់បាយ ។ ខ្ញុំងើបទៅធ្វើការតាំងពីម៉ោង៤ណោះ ។

ពេលយប់ខែភ្លឺ ក៏ធ្វើដែរ គេឲ្យវែកដី វាស់ម៉ែត្រចែកគ្នា ។ អ្នកស្លាប់ដោយអត់បាយច្រើនជាងអ្នកស្លាប់ដោយជម្ងឺ ។ រវាងអ្នកជាប់គុកនិងអ្នកនៅខាងក្រៅគឺមិនដូចគ្នាទេ គេនៅខាងក្រៅគេអាចដើរហើយទៅណាបាន ចំណែកខ្ញុំអត់ទេ ។

ខ្ញុំឈ្មោះមាស រុំ អាយុ៣៨ រស់នៅភូមិព្រៃខ្នុង ឃុំវាល ។